00989365

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 06 / 2014
ម៉ោង (Time/Heure): 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E301/13

**ការិយាល័យរដ្ឋបាល**

ល.ខ ១០៣៤២.អ.វ.ត.ក.សរ **អនុស្សរណៈអន្តរការិយាល័យ**

**សាធារណៈ / Public**

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤

**ជូនចំពោះ៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ពី៖** ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃការិយាល័យរដ្ឋបាល

**កម្មវត្ថុ៖** **អនុសាសន៍របស់អ្នកជំនាញលើការថែទាំសុខភាពរបស់ជនជាប់ចោទ**

**យោង៖**
- សេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ លើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ
- សេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ លើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ

យោងសេចក្តីសម្រេចខាងលើ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យការិយាល័យរដ្ឋបាលគាំទ្រ អង្គភាពពេទ្យ មន្ទីរឃុំឃាំង និងផ្នែករដ្ឋបាលតុលាការនៃអ.វ.ត.ក ក្នុងការអនុវត្តអនុសាសន៍របស់អ្នកជំនាញ ដែលមាននៅក្នុងកថាខ័ណ្ឌ ១៥, ១៦, ៣៩ និង ៤០ នៃរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹង នួន ជា និងនៅ ក្នុងកថាខ័ណ្ឌ ១២ (ង), ១៦ និង ៣៩ នៃរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹង ខៀវ សំផន។

ការិយាល័យរដ្ឋបាល បានសម្របសម្រួលជាមួយមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត និង អង្គភាពពេទ្យប្រចាំនៅ អ.វ.ត.ក និងមន្ទីរឃុំឃាំងដើម្បីអនុវត្តតាមអនុសាសន៍របស់អ្នកជំនាញ។ អ្នកសម្រប សម្រួលគម្រោងព្យាបាលជនជាប់ចោទ នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានបញ្ជាក់ពីការអនុវត្តន៍តាមអនុសាសន៍នេះ ដូចមានរៀបរាប់នៅក្នុងលិខិតចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៤ ដូចមានភ្ជាប់មកជាមួយ។

ការិយាល័យរដ្ឋបាល នៅតែបន្តសហការឲ្យបានល្អជាមួយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងអង្គភាពពេទ្យប្រចាំនៅ អ.វ.ត.ក ទាក់ទងនឹងការថែទាំសុខភាពទូទៅរបស់ជនជាប់ចោទ នៃមន្ទីរឃុំឃាំងបណ្តោះអាសន្ននៃ អ.វ.ត.ក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានអង្គជំនុំជម្រះសាលាដំបូង ជ្រាបជាព័ត៌មាន។